# លទ្ធផលសង្ខេបនៃការស្រាវជ្រាវៈ ការសិក្សាអំពីអ្នកបម្រើសេវាផ្លូវភេទដោយប្រយោល មកពីឧស្សាហកម្មកាត់ដេរ

*ខែ កក្កដា ឆ្នាំ ២០១០*

## សាវតារ

**កាលពីពេលថ្មីៗនេះ អង្គការពលកម្មអន្តរជាតិបានធ្វើការសិក្សាស្រាវជ្រាវជាច្រើន ដើម្បីស្វែងយល់ពីផលប៉ះពាល់ដែលឱនភាពសេដ្ឋកិច្ចជាសកលមានមកលើឧស្សាហកម្មកាត់ដេរកម្ពុជា។** គោលបំណងចម្បងនៃការសិក្សាទាំងនេះ គឺដើម្បីពង្រឹងការយល់ដឹងរបស់យើងទាំងអស់គ្នាអំពីផលប៉ះពាល់នៃឱនភាពនេះនៅកម្រិតបុគ្គល សហគ្រាស និងវិស័យ ពិនិត្យមើលលើវិធានការឆ្លើយតបដែលបានយកមកប្រើប្រាស់ និងជួយដល់ការតាក់តែង និងការអនុវត្តគោលនយោបាយ ក៏ដូចជាអន្តរាគមន៍ជាក់ស្តែងនានា សំដៅគាំទ្រដល់ការងើបឡើងវិញរបស់ឧស្សាហកម្ម និងដល់កម្មករនិយោជិតរបស់ឧស្សាហកម្មនេះ ទាំងអ្នកដែលកំពុងមានការងារធ្វើ និងអ្នកដែលបាត់បង់ការងារ ឱ្យពួកគេទទួលបានការងារសមរម្យប្រកបដោយផលិតភាពនិងទទួលបានការការពារពីសង្គម។

**លទ្ធផលសង្ខេបនៃការស្រាវជ្រាវនេះបង្ហាញពីលទ្ធផលរកឃើញនៃការសិក្សាបន្ថែមតូចមួយ ដែលពិនិត្យលើស្ថានភាពដ៏លំបាករបស់កម្មការនីមួយក្រុម ដែលតែងត្រូវបានគេលើកមកនិយាយច្រើន ប៉ុន្តែត្រូវបានគេយល់ដឹងតិចតួច ពោលគឺកម្មការនី ដែលបានចាកចេញពីការងារក្នុងរោងចក្រក្នុងពេលមានវិបត្តិកើតឡើង ហើយបានមកចាប់ផ្តើមធ្វើការងារជាអ្នកបម្រើសេវាផ្លូវភេទដោយប្រយោល នៅក្នុងវិស័យកម្សាន្តសប្បាយ។** ការសិក្សានេះផ្តោតសំខាន់លើភាពងាយរងគ្រោះរបស់កម្មករនិយោជិតដោយសារមេរោគអេដស៍ ជំងឺអេដស៍ដែលជាបញ្ហាដ៏សំខាន់បំផុតមួយក្នុងចំណោមបញ្ហានានាដែលកើតឡើងនៅកន្លែងធ្វើការនៅក្នុងប្រទេសកម្ពុជា។

**សេចក្តីពិពណ៌នានៅក្នុងការសិក្សានេះបង្ហាញពីស្ថានភាព ដែលគេតែងចង់ដឹងចង់ឮ អំពីកម្មការនីមួយក្រុម ដែលតែងតែទទួលរងការប្រកាន់គំនិតជាអវិជ្ជមាន។** ការប្រកាន់គំនិតបែបនេះមិនត្រឹមតែធ្វើឱ្យកម្មការនីទាំងនេះអាប់ឱនកិត្តិយសក្នុងនាមជាមនុស្សដូចគេដូចឯងប៉ុណ្ណោះទេ វាថែមទាំងប៉ះពាល់ដល់លទ្ធភាពរបស់ពួកគេក្នុងការទាមទារសិទ្ធិមនុស្ស និងអត្ថប្រយោជន៍ជាមូលដ្ឋាននានា ដែលពួកគេគួរទទួលបានថែមទៀតផង លើសពីនេះ វាបានរុញច្រានពួកគេឱ្យធ្លាក់ចូលទៅក្នុងស្ថានភាពកាន់តែលំបាកថែមទៀត ធ្វើឱ្យពួកគេមិនអាចទទួលបានសេវាសុខភាព និងសេវាអប់រំសំខាន់បាន។ ដូច្នេះ គោលបំណងចុងក្រោយរបស់ការសិក្សានេះ គឺដើម្បីស្វែងយល់ឱ្យកាន់តែច្បាស់អំពីស្ថានភាពរបស់កម្មការនីទាំងនេះ ដើម្បីឱ្យយើងអាចផ្តល់ឱ្យពួកគេនូវជំនួយជាក់ស្តែង សម្រាប់ជួយកាត់បន្ថយភាពងាយរង គ្រោះដោយសារមេរោគអេដស៍ដែលពួកគេកំពុងជួបប្រទះ។

*ការសិក្សានេះត្រូវបានធ្វើឡើង ដោយទីភ្នាក់ងារអភិវឌ្ឍន៍របស់ប្រទេសអូស្ត្រាលី មានឈ្មោះថា Union Aid Abroad – APHEDA ដែលជាទីភ្នាក់ងារមានបទពិសោធន៍ធ្វើការងារជាច្រើន ជាមួយអ្នកបម្រើសេវាផ្លូវភេទដោយផ្ទាល់ និងដោយប្រយោល នៅក្នុងប្រទេសកម្ពុជា (២៥ ឆ្នាំ) អ្នកចូលរួមនៅ*

*ក្នុងការសិក្សានេះ ត្រូវបានកំណត់ដោយទីភ្នាក់ងារអភិវឌ្ឍន៍ស្ត្រីកម្ពុជា ជាអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុកមួយ ដែលធ្វើការងារជុំវិញបញ្ហាជាច្រើន ដើម្បីលើកកម្ពស់សិទ្ធិសេដ្ឋកិច្ចនិងសង្គមរបស់ស្ត្រី។*

## វិធីសាស្ត្រ

**ការសម្ភាសបែបគុណវិស័យ ត្រូវបានធ្វើឡើងជាមួយអតីតកម្មការនីរោងចក្រចំនួន ១៦ នាក់ ដែលត្រូវបានគេបញ្ឈប់ពីការងារ ក្នុងកំឡុងពេលមានវិបត្តិសេដ្ឋកិច្ច ហើយដែលបច្ចុប្បន្នកំពុងធ្វើការងារនៅក្នុងវិស័យកម្សាន្តសប្បាយនិងផ្តល់សេវាផ្លូវភេទក្នុងទីក្រុងភ្នំពេញ[9]។**

**បន្ទាប់ពីការសម្ភាសនេះ ការពិភាក្សាក្រុមគោលដៅចំនួនពីរ ក្នុងមួយក្រុមមានស្ត្រី ៨ នាក់ ត្រូវបានធ្វើឡើង** ដើម្បីបញ្ជាក់ និងស្វែងយល់បន្ថែមទៀតលើព័ត៌មាន ដែលប្រមូលបានក្នុងការសម្ភាស បន្ទាប់មកព័ត៌មានស៊ីជម្រៅ ដែលទទួលបាន ត្រូវបានយកមកសំយោគចេញជាករណីសិក្សាខ្លីៗផ្តោតលើប្រធានបទដូចខាងក្រោម៖

- *ជីវភាពរស់នៅកាលនៅវ័យកុមារ*
- *បទពិសោធន៍ក្នុងវិស័យកាត់ដេរ*
- *បទពិសោធន៍ក្នុងវិស័យកម្សាន្តសប្បាយ*
- *បទពិសោធន៍ធ្វើការងារជាអ្នកបម្រើសេវាផ្លូវភេទដោយប្រយោល*
- *ការផ្លាស់ប្តូរជីវភាពរស់នៅ នៅពេលប្តូរពីមុខរបរមួយទៅមុខរបរមួយទៀត និងផលប៉ះពាល់គួរឱ្យកត់សម្គាល់ដោយសារវិបត្តិសេដ្ឋកិច្ច*
- *ការប្រើប្រាស់ស្រោមអនាម័យជាមួយអតិថិជននិងអ្នកមិនមែនជាអតិថិជន*

### លក្ខណៈវិនិច្ឆ័យសម្រាប់ជ្រើសរើសកម្មករនិយោជិត៖

1. *ធ្លាប់ធ្វើការងារក្នុងរោងចក្រកាត់ដេរកាលពីពេលថ្មីៗនេះ*
2. *កំពុងធ្វើការងារជាអ្នកបម្រើសេវាកម្សាន្តសប្បាយ ដូចជា ក្នុងហាងខារ៉ាអូខេ កន្លែងម៉ាស្សា អ្នកអង្គុយកំដរភ្ញៀវ អ្នករត់តុ ឬអ្នកផ្សព្វផ្សាយស្រាបៀរ*
3. *បច្ចុប្បន្ន កំពុងពាក់ព័ន្ធនឹងការបម្រើសេវាផ្លូវភេទដោយប្រយោល ដូចជាផ្តល់សេវាផ្លូវភេទជាថ្នូរនឹងប្រាក់ ឬផលប្រយោជន៍ជាសម្ភារៈដទៃទៀតបន្ថែមពីលើការងារគោលរបស់ខ្លួន*

### លក្ខណៈទូទៅ៖ កម្មការនីដែលត្រូវបានអង្កេត

- **កម្មករនិយោជិតទាំងអស់មានអាយុពី១៧ទៅ៣៨ឆ្នាំ** ដោយអាយុមធ្យមគឺ ២៥ឆ្នាំ
- **ពួកគេភាគច្រើនមកពីគ្រួសារក្រីក្ររស់នៅតាមជនបទនិងពាក់កណ្តាលជនបទ**ដោយឪពុកម្តាយជាអ្នកប្រកបរបរបង្កបង្កើនផលនិង ឬជាអ្នកលក់ដូរបន្តិចបន្តួច។ ពួកគេភាគច្រើនមកពីគ្រួសារដែលមានកូនលើសពី៥នាក់
- **ស្ត្រីភាគច្រើនចាប់ផ្តើមធ្វើការងារតាំងពីអាយុទើបជាង១០ឆ្នាំ**ជាអ្នកលក់ដូរតាមផ្លូវ អ្នកបម្រើការងារតាមផ្ទះ និងជួយរបររកស៊ីរបស់គ្រួសារ។

---

[9] ការពិភាក្សាក្រុមគោលដៅសរុបចំនួន៦ត្រូវបានធ្វើឡើង_៤មុននិង២ក្រោយការសម្ភាសស៊ីជម្រៅ ការពិភាក្សាក្រុមគោលដៅនីមួយៗដែលធ្វើឡើងក្រោយការសម្ភាសចូលរួមដោយស្ត្រីចំនួន៨នាក់មកពីក្រុមគោលដៅ ប៉ុន្តែមិនមានការចូលរួមពីអ្នកដែលបានចូលរួមក្នុងការពិភាក្សាក្រុមគោលដៅមុនៗ ឬក្នុងការសម្ភាសស៊ីជម្រៅឡើយ។

- **ស្ត្រីភាគច្រើនរៀនចប់ត្រឹមថ្នាក់ទី ១ ដល់ថ្នាក់ទី ៧** ដោយកម្រិតអប់រំជាមធ្យមត្រឹមថ្នាក់ទី ៤។ មូលហេតុចំបងបំផុតដែលធ្វើឱ្យពួកគេឈប់រៀនគឺ (ក)ភាពក្រីក្រ និង (ខ)ជំនឿវប្បធម៌ (ដែលថាស្ត្រីគួរនៅធ្វើការងារផ្ទះវិញប្រសើរជាង)
- **អ្នកឆ្លើយតបប្រមាណពាក់កណ្តាលបានរៀបការ នៅពេលពួកគេមានអាយុជិតម្ភៃ ឬអាយុជាងម្ភៃឆ្នាំ** ប៉ុន្តែភាគច្រើនក្រោយមកបានលែងលះគ្នាវិញ
- **ស្ត្រីមួយភាគបួនមានកូនរួចហើយ** កូនភាគច្រើនកំពុងត្រូវបានសាច់ញាតិជួយមើលថែ ហើយស្ត្រីទាំងនេះជាអ្នកជួយឧបត្ថម្ភថវិកា
- **ស្ត្រីស្ទើរតែទាំងអស់ ដែលបានសាកសួរ ឆ្លើយថា ពួកគេឈប់ធ្វើការងាររោងចក្រ ដោយសារតែវិបត្តិសេដ្ឋកិច្ចជាសកល** បើទោះបីជាមិនអាចផ្ទៀងផ្ទាត់ថាតើមូលហេតុនេះពិត ឬមិនពិតក៏ដោយ។ ស្ត្រីម្នាក់លាលែងពីការងារក្នុងរោងចក្រ មុនពេលដែលវិបត្តិហិរញ្ញវត្ថុកើតមានឡើងហើយម្នាក់ទៀតត្រូវបានគេបណ្តេញចេញដោយសារតែធ្វើការងារមិនបានល្អ។
- **ក្នុងចំណោមស្ត្រីផ្សេងទៀត មានពាក់កណ្តាលត្រូវបានគេបញ្ឈប់ពីការងារ ដោយសារតែរោងចក្របិទទ្វារ។** ពាក់កណ្តាលទៀតត្រូវបានគេបញ្ចប់កិច្ចសន្យាមុនពេលបិទរោងចក្រ ដោយសារតែពួកគេតវ៉ារឿងប្រាក់ឈ្នួល ដែលអាច ឬមិនអាចមានការពាក់ព័ន្ធជាមួយនឹងស្ថានភាពសេដ្ឋកិច្ច។

# លទ្ធផលរកឃើញសំខាន់ៗ

## ភាពងាយរងគ្រោះពាក់ព័ន្ធនឹងមេរោគអេដស៍

ភាពងាយរងគ្រោះពាក់ព័ន្ធនឹងមេរោគអេដស៍របស់អ្នកបម្រើការងារក្នុងវិស័យកម្សាន្តសប្បាយ មានទំនាក់ទំនងយ៉ាងជិតស្និទជាមួយនឹងល័ក្ខខ័ណ្ឌការងារជាផ្លូវការរបស់ពួកគេ។ ភាពងាយរងគ្រោះជាច្រើន កើតឡើងដោយសារបញ្ហារចនាសម្ព័ន្ធ និងបញ្ហាគោលនយោបាយ ហើយការកែលម្អលក្ខខណ្ឌការងារជារួម នឹងអាចកាត់បន្ថយភាពងាយរងគ្រោះដោយសារមេរោគអេដស៍របស់ពួកគេបាន។

### អំពើហិង្សា និងការរំលោភបំពាននៅកន្លែងធ្វើការ

អ្នកបម្រើសេវាកម្សាន្តសប្បាយទាំងអស់សុទ្ធតែធ្លាប់ជួបប្រទះការរំលោភបំពាននៅកន្លែងធ្វើការ ក្នុងទម្រង់មួយចំនួន ចាប់ពីការបំពារបំពានជាពាក្យសម្តី រហូតដល់ការបៀតបៀនលើរូបរាងកាយ និងផ្លូវភេទក្នុងទម្រង់ធ្ងន់ធ្ងរ។ ប៉ុន្តែ ករណីរំលោភបំពានភាគច្រើនកើតឡើង នៅកន្លែងធ្វើការជាផ្លូវការរបស់ពួកគេ ជាជាងនៅក្នុងបរិបទនៃការងារបម្រើសេវាផ្លូវភេទរបស់ពួកគេ (ស្ត្រីម្នាក់ដែលបានសម្ភាសធ្លាប់ត្រូវបានប្អូនប្រុសរបស់ថៅកែរបស់នាងចាប់រំលោភនៅកន្លែងធ្វើការរបស់នាង)។

### កង្វះជំនាញដើម្បីចរចាអំពីសុវត្ថិភាព

អ្នកបម្រើសេវាកម្សាន្តសប្បាយថ្មីៗជាច្រើននាក់ ដែលទើបចូលមកធ្វើការងារក្នុងវិស័យនេះ ក្នុងពេលមានឱនភាពសេដ្ឋកិច្ច មិនមានបទពិសោធន៍ក្នុងការចរចាដោះខ្លួនពីការស្នើសុំរួមភេទដែលពួកគេមិនចង់ ពីសំណាក់អតិថិជន និងបុគ្គលិកជាបុរស ឬអតិថិជនដែលស្រវឹងដែលគ្មានហេតុផលឬដែលតែងចង់រំលោភបំពាននោះទេ។

### សម្ពាធមិនប្រើប្រាស់ស្រោមអនាម័យជាមួយអតិថិជន

ជាមួយនឹងប៉ាន់គុំ ដែលមានកម្រិតបែបនេះ ការប្រើប្រាស់ស្រោមអនាម័យជាមួយភ្ញៀវហាក់បីដូចជាមានកម្រិតខ្ពស់ នៅក្នុងចំណោមអ្នកបម្រើសេវាកម្សាន្តសប្បាយ ដែលបម្រើសេវាផ្លូវភេទ ប៉ុន្តែដោយសារតែភ្ញៀវហ៊ានចំណាយលុយ ដើម្បីរួមភេទដោយមិនប្រើស្រោមអនាម័យ និងដោយសារតែឱនភាពសេដ្ឋកិច្ច ស្រ្តីអាចស្ថិតក្នុងស្ថានភាពមួយ ដែលធ្វើឱ្យពួកគេមានការពិបាក ក្នុងការចរចាឱ្យមានការប្រើប្រាស់ស្រោមអនាម័យ។

- **ការប្រើប្រាស់ស្រោមអនាម័យកម្រិតទាបជាមួយដៃគូដែលមិនមែនជាភ្ញៀវ**

ស្រ្តីស្ទើរតែទាំងអស់ ដែលបានសម្ភាស សុទ្ធតែបានរាយការណ៍ថាបានរួមភេទ ដោយមិនប្រើប្រាស់ស្រោមអនាម័យ ជាមួយនឹងដៃគូមិនមែនជាភ្ញៀវ ដូចជា ប្តី និងសង្សាររបស់ពួកគេ ជាដើម។ ពួកគេក៏បានរាយការណ៍ថាបានរួមភេទ ដោយមិនប្រើប្រាស់ស្រោមអនាម័យជាមួយបុរស ដែលពួកគេមិនចាត់ទុកថាជាភ្ញៀវ ប៉ុន្តែជាអ្នកដែលផ្តល់អំណោយជាទៀងទាត់ ប្រាក់កាស និងការឧបត្ថម្ភក្នុងទម្រង់ដទៃទៀតមកឱ្យពួកគេ។

- **ការបង្ខំឱ្យប្រើគ្រឿងស្រវឹង**

ការប្រើគ្រឿងស្រវឹងច្រើន គឺជាបញ្ហាចម្បងមួយសម្រាប់អ្នកបម្រើសេវាកម្សាន្តសប្បាយ នៅក្នុងប្រទេសកម្ពុជា។ ភ្ញៀវតែងរំពឹង ថាអ្នកបម្រើសេវាកម្សាន្តសប្បាយគួរតែអាចអង្គុយ ផឹកគ្រឿងស្រវឹង និងកំដរពួកគេ នៅពេលដែលពួកគេស្នើទៅកាន់ស្រ្តីទាំងនេះ។ អ្នកចូលរួមនៅក្នុងការពិភាក្សាក្រុមគោលដៅនៅក្នុងហាងខារ៉ាអូខេមួយរាយការណ៍ថាពួកគេផឹកស្រាបៀរពី១០ទៅ១២កំប៉ុងក្នុងមួយយប់។ ។ ស្រ្តីពីរនាក់ដែលបានសម្ភាសត្រូវបានគេបង្ខំឱ្យផឹករហូតដល់បាត់បង់ស្មារតី។

## ការបម្រើសេវាផ្លូវភេទរកចំណូលបន្ថែមពីលើការងារបម្រើសេវាកម្សាន្តសប្បាយ

- **ស្រ្តីដែលត្រូវបានសម្ភាស បានចាប់ផ្តើមរកចំណូលបន្ថែម តាមរយៈបម្រើសេវាផ្លូវភេទក្រៅផ្លូវការ បន្ទាប់ពីពួកគេបានទទួលរងការរំលោភបំពានពាក់ព័ន្ធនឹងការងារជាច្រើនលើកច្រើនសារ នៅក្នុងជីវិតរបស់ពួកគេ** ចាប់ផ្តើមពីការបង្ខិតបង្ខំឱ្យធ្វើការងារនៅពេលដែលពួកគេនៅវ័យកុមារនៅឡើយ, ការរំលោភបំពាន នៅពេលដែលពួកគេធ្វើការងារតាមផ្ទះ, ការធ្វើបាប នៅពេលធ្វើការងារក្នុងរោងចក្រ, ការបន្ទោសបង្អាប់ដោយអ្នកគ្រប់គ្រង និងអតិថិជន នៅពេលដែលពួកគេធ្វើការងារជាអ្នកបម្រើសេវាកម្សាន្តសប្បាយ។

- **ចំពោះអ្នកបម្រើសេវាទាំងអស់ដែលត្រូវបានសម្ភាស បានឱ្យដឹងថា ការសម្រេចចិត្តរកចំណូលបន្ថែមជាមួយនឹងការបម្រើសេវាផ្លូវភេទជាមួយភ្ញៀវ គឺ ដោយសារតែតម្រូវការហិរញ្ញវត្ថុ** ដូចជា តម្រូវការចំណូលបន្ថែម ដើម្បីរ៉ាប់រងការចំណាយលើការស្នាក់នៅ អាហារ និងការ ផ្ញើរប្រាក់ទៅផ្ទះ។ ពួកគេភាគច្រើនធ្វើការសម្រេចចិត្តបែបនេះដោយខ្លួនឯង ហើយមានតែមួយចំនួនតូចប៉ុណ្ណោះដែលត្រូវបានបញ្ចុះបញ្ចូលដោយអ្នកដទៃ។

- **និន្នាភាពសេដ្ឋកិច្ចបច្ចុប្បន្ន រួមផ្សំជាមួយនឹងការផ្លាស់ប្តូរផ្សេងៗនៅក្នុងច្បាប់ជាតិ**[២] **បានធ្វើឱ្យស្ត្រីវ័យក្មេងជាច្រើនពាន់នាក់ ចូលមកក្នុងវិស័យកម្សាន្តសប្បាយ**ដែលការបម្រើសេវាផ្លូវភេទក្រៅផ្លូវការ(ដោយលាក់កំបាំង) កំពុងជំនួសការបម្រើសេវាផ្លូវភេទជាផ្លូវការនៅតាមផ្ទះបន[៣] ។

- **នៅពេលដែលស្ត្រីចូលបម្រើសេវាកម្សាន្តសប្បាយ និងសេវាផ្លូវភេទដោយប្រយោល ពួកគេមិនត្រូវបានគ្របដណ្តប់ដោយកម្មវិធីប្រើប្រាស់ស្រោមអនាម័យ ១០០% ដែលធ្លាប់ទទួលបានជោគជ័យនោះឡើយ**[៤]។ លើសពីនេះទៅទៀត ដោយសារតែនគរបាលចាត់ទុកការដាក់ស្រោមអនាម័យតាមខ្លួន ថាជាការបង្ហាញពីការបម្រើសេវាផ្លូវភេទដោយខុសច្បាប់ នេះជាកត្តារារាំងមិនឱ្យមានការបន្តផ្សព្វផ្សាយព័ត៌មានអំពីមេរោគអេដស៍ ជំងឺអេដស៍ ដល់អ្នកបម្រើសេវាផ្លូវភេទក្រៅផ្លូវការ នៅពេលដែលពួកគេកំពុងត្រូវការព័ត៌មានបំផុត។

- **អ្នកបម្រើសេវាមួយចំនួន ជាពិសេស អ្នកម៉ាស្សា និងអ្នករត់តុ ទទួលបានប្រាក់ឈ្នួលយ៉ាងទាបពីការងាររបស់ពួកគេ ដែលធ្វើឱ្យការបម្រើសេវាផ្លូវភេទក្លាយជាយុទ្ធសាស្ត្រមួយដើម្បីឱ្យពួកគេអាចបំពេញតម្រូវការរបស់ពួកគេបាន។**

- **ជាធម្មតា ការចរចាអំពីការរួមភេទជាមួយភ្ញៀវ ធ្វើឡើងដោយផ្ទាល់នៅកន្លែងធ្វើការ រវាងស្ត្រីបម្រើសេវា និងភ្ញៀវ។** នៅពេលមានការព្រមព្រៀងគ្នាលើការរួមភេទរួចហើយ ស្ត្រីផ្សព្វផ្សាយស្រាបៀរ ស្ត្រីរត់តុ និងស្ត្រីអង្គុយកំដរភ្ញៀវ នឹងរៀបចំជួបជាមួយ ភ្ញៀវនៅផ្ទះសំណាក់ដែលនៅជិតនោះ បន្ទាប់ពីនាងចេញពីកន្លែងធ្វើការ ចំពោះស្ត្រីដែលធ្វើការងារនៅតាមហាងម៉ាស្សានិង ហាងខារ៉ាអូខេនៅតាមហាងរបស់ពួកគេមានបន្ទប់តូចៗសម្រាប់ជួលប្រចាំម៉ោង។

- **ទំនាក់ទំនងរបស់ស្ត្រីជាមួយផ្ទះសំណាក់ហាក់បីដូចជាមានសារៈសំខាន់ចំពោះសុវត្ថិភាពរបស់ពួកគេ។** អ្នកបម្រើសេវាមួយចំនួនពឹងផ្អែកលើសន្តិសុខនៅតាមផ្ទះសំណាក់ដើម្បីការពារ និងផ្តល់ស្រោមអនាម័យដល់ពួកគេ។

## ការប្រៀបធៀបជីវិតក្នុងរោងចក្រជាមួយការងារបម្រើសេវាកម្សាន្តសប្បាយនិងការងារបម្រើសេវាផ្លូវភេទ៖

- **អ្នកបម្រើសេវាស្ទើរតែទាំងអស់ដែលបានសម្ភាសចង់ធ្វើការងារបម្រើសេវាកម្សាន្តសប្បាយជាជាងធ្វើការងារក្នុងរោងចក្រកាត់ដេរ** ពួកគេភាគច្រើនគិតថា ជីវិតនៅក្នុងរោងចក្រពិបាកជាង បានប្រាក់ឈ្នួលតិច ធ្វើការងារច្រើនម៉ោង លក្ខខណ្ឌ ការងារមិនល្អ (និងមិនធ្វើឱ្យពួកគេមានសុខភាពល្អ) ហើយអ្នកគ្រប់គ្រងត្រួតត្រាហួសហេតុពេក។

---

[២] នេះគឺសំដៅលើការអនុវត្តច្បាប់ប្រឆាំងការជួញដូរមនុស្សបច្ចុប្បន្ន (អនុម័តនៅក្នុងឆ្នាំ ២០០៨) ដែលចាត់ទុកទង្វើពេស្យាចារគឺជាបទល្មើស ព្រហ្មទណ្ឌធ្វើឱ្យមានការផ្លាស់ប្តូរយ៉ាងច្រើននៃរបៀបធ្វើអាជីវកម្មផ្លូវភេទ និងរបៀបរកសេវាផ្លូវភេទនៅក្នុងប្រទេសកម្ពុជា(ដូចជាចេញពីផ្ទះបនដែលឥឡូវនេះត្រូវបានគេចាត់ទុកថាខុសច្បាប់ទៅតាមកន្លែងបម្រើសេវាកម្សាន្តសប្បាយដូចជាហាងខារ៉ាអូខេ ហាងម៉ាស្សា និងបៀរហ្គាដិនជាដើម)។

[៣] តួលេខបង្ហាញ ដែលទទួលបានពីទិន្នន័យ(រួមគ្នា) របស់NCHAD និង KHANA បង្ហាញពីការកើនឡើងនូវនិយោជិតក្នុងវិស័យកម្សាន្តសប្បាយចំនួន១៤,១២៨ នាក់រវាងឆ្នាំ ២០០៨ និង ២០០៩ (សូមមើលរបាយការណ៍ពេញទំព័រទី១៤អំពីការបែងចែកទៅតាមប្រភេទគ្រឹះស្ថាន)។

[៤] គោលនយោយប្រើប្រាស់ស្រោមអនាម័យ១០០% ត្រូវបានរៀបចំឡើងជាពិសេសសម្រាប់ផ្ទះបនហើយត្រូវបានគេចាត់ទុកថាជាក្របខ័ណ្ឌច្បាប់មួយ ដែលផ្តល់លទ្ធភាពឱ្យភ្នាក់ងារសុខភាពចុះផ្តល់សេវាដល់អ្នកបម្រើសេវាផ្លូវភេទ គោលនយោបាយនេះមិនគ្របដណ្តប់លើគ្រឹះស្ថានមិនមែនផ្ទះបន(ដូចជាហាងម៉ាស្សា បៀរហ្គាដិន និងហាងខារ៉ាអូខេ)ដែលជាកន្លែងបម្រើឬស្វែងរកសេវាផ្លូវភេទនោះឡើយ។

- **តាមរយៈការផ្តល់សេវាបម្រើផ្លូវភេទ បន្ថែមពីលើការងារបម្រើសេវាកម្សាន្តសប្បាយ អ្នកបម្រើសេវាបាននិយាយថា ពួកគេអាចផ្គត់ផ្គង់ខ្លួនឯង និងឧបត្ថម្ភដល់គ្រួសាររបស់ខ្លួនបានប្រសើរជាងមុន។** ពួកគេក៏ឯកភាពផងដែរថា ការងារទាំងនេះមានចំនួនម៉ោងធ្វើការតិច ហើយផ្តល់ឱ្យពួកគេនូវសេរីភាពច្រើនជាងការងារក្នុងរោងចក្រ។

- **មានការយល់ឃើញផ្សេងៗគ្នាអំពីថាតើស្ត្រីបម្រើសេវាទាំងនេះគ្រោងបន្តធ្វើការងារបម្រើសេវាកម្សាន្តសប្បាយ និងការងារបម្រើសេវាផ្លូវភេទ នាពេលអនាគត ដែរឬទេ។** ប៉ុន្តែ បើទោះបីជាការងារនេះមានការលំបាកក៏ដោយ ក៏ពួកគេភាគច្រើនគិតថាការងារទាំងនេះ ល្អជាងការងារក្នុងឧស្សាហកម្មកាត់ដេរ ហើយ ពួកគេជាច្រើននាក់ថែមទាំងនិយាយផងដែរថា ពួកគេនឹងបដិសេធការងារក្នុងរោងចក្រចោលប្រសិនបើមានគេផ្តល់ការងារនេះឱ្យពួកគេធ្វើម្តងទៀត។

## ករណីសិក្សា

ខាងក្រោមនេះ ជាឧទាហរណ៍ករណីសិក្សាចំនួន ៣ អំពីស្ត្រី ដែលត្រូវបានគេបញ្ឈប់ការងារពីវិស័យកាត់ដេរ ហើយដែលឥឡូវនេះកំពុងធ្វើការងារជាអ្នកបម្រើសេវាកម្សាន្តសប្បាយ និងជាអ្នកបម្រើសេវាផ្លូវភេទដោយប្រយោល នៅក្នុងក្រុងភ្នំពេញ ទម្រង់ពេញលេញនៃរឿងរ៉ាវទាំងនេះ និងរឿងរ៉ាវរបស់អ្នកបម្រើសេវាផ្សេងទៀត មាននៅក្នុងរបាយការណ៍ចុងក្រោយ (អាចរកបានពីគេហទំព័ររបស់ *រោងចក្រកាន់តែប្រសើរនៅកម្ពុជា*)

***ផារី អាយុ២៦ឆ្នាំ មកពីខេត្តបាត់ដំបង***

*បន្ទាប់ពីធ្វើការងារឡើងចុះ នៅក្នុងវិស័យកាត់ដេរជិត ១០ ឆ្នាំរួចមក ផារីបានបាត់បង់ការងារក្នុងរោងចក្ររបស់នាង នៅ ក្នុងឆ្នាំ ២០០៩ ឥលូវនេះនាងកំពុងធ្វើការងារជាអ្នកផ្សព្វផ្សាយស្រាបៀរនៅក្នុងទីក្រុងភ្នំពេញ។*

*ដោយមានឱកាសតិចតួច និងការលំបាកផ្នែកហិរញ្ញវត្ថុកាន់តែមានច្រើនឡើងៗ (នាងមិនបានទទួលប្រាក់បំណាច់អ្វីទាំងអស់ពីរោងចក្ររបស់នាង នៅពេលរោងចក្រនេះបិទទ្វារ) ដំបូង ផារីរកបានការងារធ្វើនៅក្នុងហាងខារ៉ាអូខេមួយ ហើយមិនយូរ ប៉ុន្មាននាងបានចាប់បម្រើសេវាផ្លូវភេទជាមួយភ្ញៀវ ដើម្បីរកចំណូលបន្ថែមពីលើការងារខារ៉ាអូខេនេះ។ ការងារបន្ថែមនេះធ្វើឱ្យនាងអាចបង្កើនចំណូលលើសពីប្រាក់ខែគោល ៦០ ដុល្លារក្នុងមួយខែរបស់នាង ហើយអាចរ៉ាប់រងចំណាយសម្រាប់ការព្យាបាលជំងឺរបស់ម្តាយនាង។*

*ប៉ុន្តែ បីខែក្រោយមក ផារីបានលាឈប់ពីការងារនេះ ហើយចាប់ផ្តើមធ្វើការងារជាអ្នកផ្សព្វផ្សាយស្រាបៀរ ពេលនេះ នាងធ្វើការងារតិចម៉ោងជាងមុន ហើយបានប្រាក់ខែច្រើនជាងមុន (ប្រហែលជា ៧០ ដុល្លារក្នុងមួយខែ) ប៉ុន្តែនាងនៅតែបម្រើសេវាផ្លូវភេទ ដើម្បីរកចំណូលបន្ថែម។ ឥលូវនេះ នាងមានភ្ញៀវ៤ ឬ៥ នាក់ក្នុងមួយខែ ដែលម្នាក់ៗត្រូវបង់៥០ ដុល្លារ ពេលរួមភេទម្តង។*

*ដោយសារការមិនចូលចិត្តការងារកាត់ដេរ និងការងារខារ៉ាអូខេ ផារីនិយាយថា នាងពេញចិត្តនឹងការងារបច្ចុប្បន្នរបស់នាងដោយសារតែវាធ្វើឱ្យនាងមានសេរីភាពច្រើនជាងមុន និងធ្វើការងារដោយគ្មានការបង្ខិតបង្ខំ ឬការត្រួតត្រាអ្វីឡើយ។ នាងអនុវត្តការរួមភេទដោយសុវត្ថិភាពជាមួយភ្ញៀវរបស់នាង ហើយជឿថានាងដឹងយ៉ាងច្បាស់អំពីមេរោគអេដស៍និងជំងឺកាមរោគ។*

***ទេវី អាយុ៣១ឆ្នាំ មកពីទីក្រុងភ្នំពេញ***

*ទេវីក៏ធ្វើការងារជាអ្នកផ្សព្វផ្សាយស្រាបៀរផងដែរ បន្ទាប់ពីរោងចក្រ ដែលនាងបានធ្វើការងាររយៈពេល ៤ ឆ្នាំ បានបិទ ទ្វារភ្លាមៗ គ្មានការរំពឹងទុកជាមុន។ បន្ទាប់ពីមានកូដកម្មជាច្រើនថ្ងៃរួចមក ទេវី និងកម្មករកម្មការនីផ្សេងទៀតបានទទួលប្រាក់បំណាច់ ៣០០ ដុល្លារពីម្ចាស់រោងចក្រ ហើយប្រាក់នេះបានជួយនាងរហូតដល់នាងរកបានការងារថ្មីធ្វើនៅក្នុងភោជនីយដ្ឋានមួយ ប៉ុន្តែ ដោយសារតែនាងលក់ស្រាបៀរមិនដាច់សោះនៅក្នុងខែទីមួយ ទេវីទទួលចំណូលបានតែពីប្រាក់ធីប និងការបម្រើសេវាផ្លូវភេទជាមួយភ្ញៀវតែប៉ុណ្ណោះ។*

*ឥឡូវនេះ ទេវីរួមភេទជាមួយភ្ញៀវ ប្រហែលជា ២ ដងក្នុងមួយខែ (តែងប្រើស្រោមអនាម័យ) ហើយទទួលបានប្រាក់ចន្លោះពី ១០ ដុល្លារទៅ១៥ដុល្លារក្នុងមួយដង។ ទេវីចាត់ទុកខ្លួនឯងថាមានសំណាងដោយសារតែឥឡូវនេះនាងអាចផ្ញើរប្រាក់បាន៣០ដុល្លារក្នុងមួយខែដើម្បីជួយឧបត្ថម្ភដល់ឪពុកម្តាយនិងប្អូនស្រីរបស់នាង។*

*ចាប់តាំងពីនាងចាកចេញពីរោងចក្រ នាងក៏ជឿផងដែរថា ជីវភាពរបស់នាងបានប្រសើរជាងមុន ហើយក៏ពេញចិត្តជាមួយនឹងសេរីភាពដែលការងារបច្ចុប្បន្ននេះផ្តល់ឱ្យនាង។*

***សុថា អាយុ២៣ឆ្នាំ មកពីខេត្តព្រៃវែង***

*សុថាធ្វើការងារជាកម្មការនីកាត់ដេរ ក្នុងរោងចក្រកាត់ដេរមួយ ដោយទទួលបានប្រាក់ឈ្នួល ៥៥ ដុល្លារ ក្នុងមួយខែ គិតរហូតមកដល់ពេលរោងចក្របិទទ្វារ នៅក្នុងឆ្នាំ ២០០៩។ បន្ទាប់ពីនាងត្រូវបានគេបញ្ឈប់ពីការងារ នាងបានមករស់នៅជាមួយគ្រួសាររបស់នាងក្នុងខេត្តកំពង់សោម ហើយរកការងារបានធ្វើជាអ្នករត់តុ។ ដំបូងឡើយ នាងមិនបានបម្រើសេវាផ្លូវភេទនោះឡើយ ហើយទទួលបានការការពារពីម្ចាស់ភោជនីយដ្ឋាន ដែលមិនអនុញ្ញាតឱ្យនាងអង្គុយកំដរភ្ញៀវឡើយ។ ប៉ុន្តែ ដោយសារតែប្រាក់ខែនាងតិច បានត្រឹមតែ ២៥ ដុល្លារក្នុងមួយខែ ទីបំផុតនាងបានសម្រេចចិត្តបម្រើសេវាផ្លូវភេទទៅឱ្យភ្ញៀវម្នាក់ ត្រឹមតែម្តងបាន១០០ដុល្លារ។*

*បច្ចុប្បន្ននេះ នាងធ្វើការងារនៅទីក្រុងភ្នំពេញជាអ្នកអង្គុយកំដរភ្ញៀវ ដោយនាងទទួលបាន ៤០ ដុល្លារក្នុងមួយខែ (រួមទាំងប្រាក់ធីប) បូករួមជាមួយនឹងការងារបម្រើសេវាផ្លូវភេទជាប្រចាំ ឥឡូវនេះ សុថារកបានប្រហែលជា ២០០ ដុល្លារក្នុងមួយ ខែ។ ខណៈពេលដែលនាងទទួលស្គាល់ថា ការងារកាត់ដេរមានការលំបាកជាងការងារបច្ចុប្បន្នរបស់នាងជាអ្នកអង្គុយកំដរភ្ញៀវ ហើយនាងអាណិតសង្សាររបស់នាងដែលមិនដឹងថានាងជាអ្នកបម្រើសេវាផ្លូវភេទ។*

*បើទោះបីជាសុថាប្រើប្រាស់ស្រោមអនាម័យជាមួយភ្ញៀវក៏ដោយ ក៏នាងប្រើស្រោមអនាម័យតែម្តងម្កាលប៉ុណ្ណោះជាមួយសង្សាររបស់នាង ហើយនឹងមិនដែលពិនិត្យរកមើលជំងឺកាមរោគឡើយ។ នៅពេលមួយ ពេលដែលនាងធ្វើការងារជាអ្នករត់តុ សុថាត្រូវបានភ្ញៀវម្នាក់ ដែលចង់រួមភេទជាមួយនឹង ភ្ជង់នាងជាមួយនឹងកាំភ្លើង។ តែទោះជាយ៉ាងណាក៏ដោយ ក៏នេះមិនអាចរារាំងនាងមិនឱ្យធ្វើការងារបម្រើសេវាផ្លូវភេទនោះដែរ។*

# អនុសាសន៍

លទ្ធផលទទួលបានពីការសិក្សានេះនិងការសិក្សាដទៃទៀតបង្កើតបានជាមូលដ្ឋានសម្រាប់អនុសាសន៍ខាងក្រោម៖

(១) **ចាប់ផ្តើមយុទ្ធនាការមួយប្រឆាំងនឹងអំពើហិង្សា និងការរំលោភបំពានផ្សេងទៀត នៅក្នុងវិស័យកម្សាន្តសប្បាយ និងឱ្យម្ចាស់និងអ្នកគ្រប់គ្រងកន្លែងកម្សាន្តសប្បាយទទួលខុសត្រូវចំពោះការរំលោភបំពានទាំងនេះ។** នេះគឺដោយសារតែមានទំនាក់ទំនងយ៉ាងច្បាស់លាស់ និងសំខាន់ រវាងការបៀតបៀន និងលក្ខខណ្ឌការងារប្រកបដោយគ្រោះថ្នាក់ ជាមួយនឹងកំណើនភាពងាយរងគ្រោះដោយសារមេរោគអេដស៍នៅតាមគ្រឹះស្ថានកម្សាន្តសប្បាយនានា។

(២) **បង្កើតសម្ភារៈអប់រំផ្សព្វផ្សាយដែលឆ្លើយតបចំពោះភាពងាយរងគ្រោះដែលបានលើកឡើងនៅក្នុងរបាយការណ៍នេះហើយធ្វើការផ្សព្វផ្សាយសម្ភារៈទាំងនេះទៅតាមកន្លែងធ្វើការងារនានា អ្នកគ្រប់គ្រងដែលជាគោលដៅ អ្នកបម្រើសេវាកម្សាន្តសប្បាយ និងអតិថិជនរបស់ពួកគេ។** សម្ភារអប់រំផ្សព្វផ្សាយបែបនេះគួរគ្របដណ្តប់លើបញ្ហា ដែលពាក់ព័ន្ធជាមួយសិទ្ធិជា មូលដ្ឋានរបស់អ្នកបម្រើសេវាដូចជាប្រាក់ឈ្នួលសមរម្យ,(ការដោះស្រាយ)បញ្ហាអសមភាពយេនឌ័រនិងការចូលរួមជាសមាជិកសហជីព។

(៣) **ដាក់បញ្ចូលគ្រឹះស្ថានកម្សាន្តសប្បាយចូលទៅក្នុងការអនុវត្តតាមប្រកាសលេខ ០៨៦ (អនុវត្តច្បាប់) ស្តីពីការបង្កើតគណៈកម្មាធិការអេដស៍ នៅតាមសហគ្រាស និងគ្រឹះស្ថាននានា និងការបង្ការមេរោគអេដស៍ ជំងឺអេដស៍ នៅកន្លែងធ្វើការ។** នេះគឺជាវេទិកាស្ថាប័នអចិន្ត្រៃយ៍មួយ ដើម្បីកាត់បន្ថយភាពងាយរងគ្រោះដោយសារមេរោគអេដស៍ របស់អ្នកបម្រើសេវាកម្សាន្តសប្បាយ។

(៤) **បង្កើតដំណើរការផ្តល់អាជ្ញាប័ណ្ណ សម្រាប់គ្រឹះស្ថានកម្សាន្តសប្បាយ ដោយដាក់បញ្ចូលនូវលក្ខខណ្ឌជាមូលដ្ឋាន ដើម្បីឱ្យនិយោជកធ្វើការអនុវត្តនិងអនុលោមតាម។**

(៥) **បង្កើតយន្តការពិនិត្យតាមដានត្រីភាគី ដើម្បីធ្វើការត្រួតពិនិត្យល័ក្ខខ័ណ្ឌនៅតាមគ្រឹះស្ថានកម្សាន្តសប្បាយឱ្យបានទៀងទាត់** ដោយធ្វើការងារក្នុងភាពជាដៃគូជាមួយក្រសួងទេសចរណ៍ នាយកដ្ឋានពេទ្យការងារ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សមាគមនិយោជកនិងសហជីព។

(៦) **ពង្រឹងកិច្ចខិតខំប្រឹងប្រែងតស៊ូមតិ ដើម្បីអនុវត្តក្រឹត្យលេខ ០៦៦ ស្តីពីការអនុវត្តកម្មវិធីប្រើប្រាស់ស្រោមអនាម័យ ១០០% នៅតាមគ្រឹះស្ថានកម្សាន្តសប្បាយ។** ទាក់ទិននឹងគោលបំណងនេះ ក្រឹត្យនេះត្រូវពិចារណាលើបរិបទពិសេសនៃការងារបម្រើសេវាផ្លូវភេទ នៅតាមកន្លែងកម្សាន្តសប្បាយ ដូចជា ការដែលអ្នកបម្រើសេវាផ្លូវភេទមិនប្រើស្រោមអនាម័យជាមួយភ្ញៀវជាប្រចាំនិងដៃគូមិនមែនជាភ្ញៀវជាដើម។

(៧) **សម្របសម្រួលឱ្យដៃគូត្រីភាគីមានតួនាទីឆ្លើយតបចំពោះភាពងាយរងគ្រោះសំខាន់ៗនៅក្នុងវិស័យកម្សាន្តសប្បាយ។** សហជីពគួរពិចារណាធ្វើការងារជាដៃគូជាមួយនឹងសមាគមអ្នកបម្រើសេវាកម្សាន្តសប្បាយដែលជាអង្គការក្រៅរដ្ឋាភិបាលដើម្បីចាប់ផ្តើមធ្វើការងារផ្តោតលើបញ្ហាសុខភាព និងសុវត្ថិភាពនៅកន្លែងធ្វើការជាមូលដ្ឋាន និងការទទួលបានសន្តិសុខ សង្គម ការពង្រឹងភាពជាដៃគូរវាងសមាគម និងសហជីព គឺជាជំហានដ៏សំខាន់មួយ ដើម្បីកែលំអល័ក្ខខ័ណ្ឌសុខភាព និង សុវត្ថិភាពរបស់អ្នកបម្រើសេវាកម្សាន្តសប្បាយ។

ចំពោះទម្រង់ពេញនៃរបាយការណ៍នេះសូមចូលមើលគេហទំព័ររបស់រោងចក្រកាន់តែប្រសើរនៅកម្ពុជា៖
www.betterfactories.org